ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម
*General Directorate of Trade Support Services*
នាយកដ្ឋាន កម្មសិទ្ធិបញ្ញា
*Department of Intellectual Property*

លេខ៖ 102 ពណ.កសប

ថ្ងៃពុធ ៥រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារទំនាក់ទំនងសាធារណៈ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

## ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២៦៩ ព.ណបល.ប្រក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីរបៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត **ក្រុមការងារទំនាក់ទំនងសាធារណៈ** របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីពង្រឹងនិងផ្សព្វផ្សាយចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាដល់សាធារណជន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **សួន វិជ្ជា** | ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២-លោក **ឡៅ រាសី** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | អនុប្រធាន |
| ៣-លោក **ឌិត សីច័ន្ទលី** | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | អនុប្រធាន |

| | | |
|---|---|---|
| ៤-លោក **តា ប៊ុនរិទ្ធ** | ប្រធានការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម | សមាជិក |
| ៥-លោក **តា ប៊ុនខៃត** | ប្រធានការិយាល័យសហប្រតិបត្តិការនិងកិច្ចការច្បាប់ | សមាជិក |
| ៦-លោក **សុខ ហុង** | ប្រធានការិយាល័យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងព័ត៌មានសម្ងាត់ពាណិជ្ជកម្ម | សមាជិក |
| ៧-លោក **លុយ សុផល្លា** | ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម | សមាជិក |
| ៨-លោកស្រី **ហ៊ី ដារ៉ា** | ប្រធានការិយាល័យចុះបញ្ជីម៉ាកអន្តរជាតិ | សមាជិក |
| ៩-លោក **លី សូណាមិន** | ប្រធានការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា | សមាជិក |
| ១០-លោក **អ៊ឹង ឆាយហុង** | អនុប្រធានការិយាល័យវិវាទ | សមាជិក |
| ១១-លោក **សុខ ទិមុល** | អនុប្រធានការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា | សមាជិក |
| ១២-លោក **ចេង រ័ត្នសុធា** | អនុប្រធានការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា | សមាជិក |
| ១៣-លោក **ឡាច សំបាត់** | អនុប្រធានការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ | សមាជិក |

**ប្រការ ២.-**

ក្រុមការងារទំនាក់ទំនងសាធារណៈ នេះ មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងដឹកនាំការងារពាក់ព័ន្ធនឹងទំនាក់ទំនងសាធារណៈ សំដៅលើកកម្ពស់ការផ្សព្វផ្សាយចំណេះដឹងកម្មសិទ្ធិបញ្ញាដល់សាធារណជន
- តាមដានរាល់សកម្មភាពពាក់ព័ន្ធនឹងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៅលើបណ្តាញសង្គម (ហ្វេសប៊ុក)ផេករបស់ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកម្មសិទ្ធិបញ្ញា និងផេកផ្លូវការផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័រនិងហ្វេកប៊ុកផេករបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញាឱ្យបានជាប់លាប់ជាប្រចាំ
- ពិនិត្យ និងសហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការរៀបចំចម្លើយឆ្លើយតបទៅនឹងចម្ងល់និងសំណួររបស់សាធារណជនពាក់ព័ន្ធនឹងការងារកម្មសិទ្ធិបញ្ញា
- រៀបចំព្រាងសំណួរ-ចម្លើយជាមុន ពាក់ព័ន្ធនឹងការងារកម្មសិទ្ធិបញ្ញា
- សហការរៀបចំឯកសារផ្សព្វផ្សាយ និងកម្មវិធីយល់ដឹងផ្សេងៗពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ចំណេះដឹងសាធារណៈស្តីពីកម្មសិទ្ធិបញ្ញា និងការប្រើប្រាស់កម្មសិទ្ធិបញ្ញាឲ្យមានប្រសិទ្ធភាពដល់មហាជន ដូចជាការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិនានា ស្ប៉តពាណិជ្ជកម្ម ល្បែងល្បងប្រាជ្ញា និងការបង្កើតគេហទំព័រអប់រំ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៣.-**

មានតែមន្ត្រីបង្គោលបីរូបដូចបានកំណត់ខាងក្រោមប៉ុណ្ណោះ ទទួលបន្ទុកឆ្លើយតបសាធារណៈជន និងធ្វើបច្ចុប្បន្នភាពគេហទំព័រ និងហ្វេសប៊ុកផេករបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា៖

| | |
|---|---|
| ១-លោក **សុខ ទិមុល** | អនុប្រធានការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា |
| ២-លោក **ចេង រ័ត្នសុធា** | អនុប្រធានការិយាល័យស្វ័យប្រវត្តិកម្មនិងព័ត៌មានវិទ្យា |
| ៣-លោក **ឡាច សំបាត់** | អនុប្រធានការិយាល័យអប់រំ និងចំណេះដឹងសាធារណៈ |

**ប្រការ ៤.-**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណី ប្រធានមានភារកិច្ចផ្សេង អនុប្រធានអាចដឹកនាំកិច្ចប្រជុំបាន តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**ប្រការ ៥**.-

លោក-លោកស្រីអនុប្រធាននាយកដ្ឋាន លោក-លោកស្រីប្រធាន-អនុប្រធានការិយាល័យ និងសាម៉ីខ្លួនដូចមាននៅក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា**

**សួន វិជ្ជា**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអគ្គនាយកនៃអគ្គនាយដ្ឋានសេវាពាណិជ្ជកម្ម
- ឯកឧត្តមអគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋាន
- ឯកសារ-កាលប្បវត្តិ